ឯកសារគោលជំហរ

# ឯកសារគោលជំហររបស់អង្គការ WHO/UNODC/UNAIDS ស្តីអំពីការព្យាបាលដោយសារធាតុជំនួស (substitution maintenance therapy) នៅក្នុងការគ្រប់គ្រងការញៀនអាភៀន និងការបង្ការជំងឺអេដស៍

អង្គការសុខភាពពិភពលោក (WHO), ការិយាល័យអង្គការសហប្រជាតិជាតិប្រឆាំងនឹងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងអង្គការ UNAIDS បានបង្កើតនូវគោលជំហររួមគ្នាស្តីអំពីការព្យាបាលដោយប្រើប្រាស់សារធាតុជំនួសក្នុងការព្យាបាលការញៀនអាភៀន ។ ដោយផ្អែកទៅលើការពិនិត្យឡើងវិញនូវភស្តុតាងវិទ្យាសាស្រ្ត និងរៀបចំឡើងសំរាប់អ្នកធ្វើគោលនយោបាយ ឯកសារគោលជំហររបស់អង្គការ WHO/UNODC/UNAIDS លើកឡើងអំពីញ្ហាជាច្រើន ចាប់តាំងពីគោលការណ៍ជាមូលដ្ឋានសំរាប់គំរូនៃការព្យាបាលនេះ រហូតទៅដល់ការយកចិត្តទុកដាក់ជាក់លាក់ទៅលើការផ្តល់ការព្យាបាលបែបនេះដល់អ្នកដែលមានជំងឺអេដស៍ ។

## សេក្តីប្រកាសរួមគ្នារបស់អង្គការ WHO/UNODC/UNAIDS ស្តីអំពីការព្យាបាលដោយប្រើប្រាស់សារធាតុជំនួស [1]

ការញៀនអាភៀន ដែលជាលក្ខខ័ណ្ឌសុខភាពស្មុគ្រស្មាញ ហើយដែលជារឿយៗទាមទារនូវការព្យាបាល និងការថែទាំយូរអង្វែងនោះ មានការប្រឈមមុខខ្ពស់ទៅនឹងការឆ្លងមេរោគអេដស៍ នៅក្នុងពេលដែលអាភៀនត្រូវបានចាក់បញ្ចូលទៅក្នុងខ្លួនដោយប្រើប្រាស់ឧបករណ៍ចាក់ដែលមានការឆ្លងរោគ ។ ការព្យាបាលការញៀនថ្នាំ គឺជាយុទ្ធសាស្រ្តដែលមានសារៈសំខាន់ ក្នុងការលើកកំពស់សុខមាលភាព និងមុខងារសង្គមរបស់បុគ្គលដែលញៀនអាភៀន និងក្នុងការកាត់បន្ថយផលវិបាកសុខភាព និងផលវិបាកសង្គមដែលបណ្តាលមកពីការប្រើប្រាស់អាភៀននេះ រួមទាំងការចំលងមេរោគអេដស៍ ។ ដោយសារតែគ្មានការព្យាបាលទោលណាមួយដែលមានប្រសិទ្ធភាពសំរាប់បុគ្គលទាំងអស់ដែលញៀនអាភៀននោះ គេត្រូវមានជំរើសច្រើន និងគ្រប់គ្រាន់នៅក្នុងការព្យាបាល ។ ការព្យាបាលដោយប្រើប្រាស់សារធាតុជំនួស (substitution maintenance therapy) គឺជាជំរើសមួយនៅក្នុងចំណោមជំរើសដែលមានប្រសិទ្ធភាពបំផុត សំរាប់ការញៀនអាភៀន ។ វាអាចកាត់បន្ថយចំណាយខ្ពស់ដោយសារការញៀនអាភៀន សំរាប់បុគ្គលដែលញៀនអាភៀន គ្រួសាររបស់គេ និងសង្គមទាំងមូល ដោយសារការកាត់បន្ថយការប្រើប្រាស់ហេរ៉ូអ៊ីន, ការស្លាប់ដែលពាក់ព័ន្ធ, ឥរិយាបទដែលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍, និងសកម្មភាពឧក្រិដ្ឋ ។ ការព្យាបាលដោយប្រើប្រាស់សារធាតុជំនួស គឺជាធាតុមួយដ៏សំខាន់របស់យុទ្ធវិធីដែលផ្អែកលើសហគមន៍ដើម្បីគ្រប់គ្រងការញៀនអាភៀន និងការបង្កការឆ្លងមេរោគអេដស៍នៅក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនដោយការចាក់ (IDUs) ។ ការផ្តល់ការព្យាបាលដោយប្រើប្រាស់សារធាតុជំនួស – ដែលត្រូវបានធ្វើឡើងដោយផ្អែកលើភ័ស្តុតាងដែលទទួលបានពីការស្រាវជ្រាវ និងដោយមានការវាយតំលៃ, ការបណ្តុះបណ្តាល, និង មានការទទួលស្គាល់ត្រឹមត្រូវ – គួរត្រូវបានគិតពិចារណាថាជាជំរើសនៃការព្យាបាលដែលមានសារៈសំខាន់ នៅក្នុងសហគមន៍ដែលមានអត្រាញៀនអាភៀនខ្ពស់ ជាពិសេសនៅក្នុងសហគមន៍ដែល IDUs ប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងមេរោគដទៃទៀតដែលឆ្លងតាមរយៈ ឈាម ។

1 នៅក្នុងឯកសារនេះពាក្យថា "ការព្យាបាលដោយប្រើប្រាស់សារធាតុជំនួស" សំដៅទៅលើការការព្យាបាលដែលបំពេញនូវលក្ខណៈវិនិច្ឆ័យដូចតទៅនេះ : សារធាតុដែលត្រូវបានប្រើប្រាស់សំរាប់ការព្យាបាលជំនួសត្រូវបានគេវាយតំលៃដោយហ្មត់ចត់, ការព្យាបាលដែលត្រូវបានធ្វើឡើងដោយអ្នកជំនាញក្នុងផ្នែកវេជ្ជសាស្រ្តដែលមានការទទួលស្គាល់, និងមានការត្រួតពិនិត្យតាមដានការព្យាបាលដោយត្រឹមត្រូវ ។

World Health Organization

UNITED NATIONS
Office on Drugs and Crime

UNAIDS
UNICEF · WFP · UNDP · UNFPA · UNODC
ILO · UNESCO · WHO · WORLD BANK

ដកស្រង់ចេញពីឯកសារគោលជំហរ...

---

"...គ្មានគំរូនៃការព្យាបាលទោលណាមួយដែលមានប្រសិទ្ធភាពសំរាប់អ្នកញៀនអាភៀនគ្រប់គ្នាទេ ។ លទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់នូវជំរើសជាច្រើន សំរាប់ការព្យាបាល គួរត្រូវបានផ្តល់អោយ ដើម្បីឆ្លើយតបទៅនឹងតំរូវការផ្សេងៗគ្នា របស់អ្នកដែលញៀនអាភៀន ។"

---

"ការព្យាបាលជំនួសគឺជាគំរូព្យាបាលដែលមានប្រសិទ្ធភាព មានសុវត្ថិភាព និងមានប្រសិទ្ធភាពចំណាយសំរាប់គ្រប់គ្រងការញៀនអាភៀន ។ ការវាយតំលៃដោយញឹកញាប់ និងហ្មត់ចត់ បានបង្ហាញថា ការព្យាបាលបែបនេះគឺជាធាតុមួយដ៏សំខាន់ និងមានតំលៃនៅក្នុងការគ្រប់គ្រងការញៀនអាភៀន និងការបង្ការការឆ្លងមេរោគអេដស៏នៅក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនដោយការចាក់ ។"

---

"មានភ័ស្តុតាងកាន់តែច្រើនឡើងថាលទ្ធផលល្អដែលទទួលបានពីការព្យាបាលជំនួស កើតឡើងពីការទទួលបាននូវការព្យាបាលទាន់ពេលវេលា រយៈពេលវែងក្នុងការព្យាបាល និងការបន្តការព្យាបាល និងក៏រិត (dose) ឱសថគ្រប់គ្រាន់ ។"

---

"អ្នកញៀនអាភៀន ទទួលផលពីការព្យាបាលជំនួស តាមរយៈការលើកកំពស់ស្ថេភាព និងការកែលំអសុខមាលភាព និងមុខងារសង្គម ។ អ្នកដែលទទួលនូវការព្យាបាលជំនួស អាចមានការរីកចំរើនយ៉ាងខ្លាំងនៅក្នុងជីវិតផ្លូវកាយ និងផ្លូវចិត្តរបស់គេ ក៏ដូចជាទំនាក់ទំនងរបស់គេជាមួយអ្នកដទៃទៀត និងសមត្ថភាពរបស់គេក្នុងការចូលរួមចំណែកប្រកបដោយអត្ថន័យដល់សហគមន៏របស់គេ និងសង្គមទាំងមូល ។"

---

"សង្គមទាំងមូលទទួលផលប្រយោជន៏ពីការព្យាបាលជំនួស ដោយសារមានការកាត់បន្ថយនូវបាតុភាពនៃការប្រព្រឹត្តបទឧក្រិដ្ឋ ការកាត់បន្ថយចំណាយទៅលើការថែទាំសុខភាព និងចំណាយលើតុលាការយុត្តិធម៌ ការកាត់បន្ថយគ្រោះថ្នាក់នៃការចំលងមេរោគអេដស៏ និងមេរោគដទៃទៀតដែលឆ្លងតាមឈាម និងកំណើនផលិតភាព ។ មានអំណះអំណាងយ៉ាងរឹងមាំ សំរាប់ការវិនិយោគទៅលើការព្យាបាលដោយប្រើប្រាស់សារធាតុជំនួសក្នុងការព្យាបាលការញៀនអាភៀន ដោយហេតុថា ប្រាក់សន្សំដែលទទួលបានពីការចំណាយព្យាបាលអ្នកជំងឺម្នាក់ មានចំនួនយ៉ាងច្រើនលើសពីការចំណាយ ។"

---

"ការផ្តល់នូវការព្យាបាលជំនួសសំរាប់ការញៀនអាភៀន គឺជាយុទ្ធសាស្ត្របង្ការជំងឺអេដស៏ដ៏មានប្រសិទ្ធភាព ដែលគួរត្រូវបានគេពិចារណាអនុវត្តន៏-អោយបានឆាប់តាមដែលអាចធ្វើបាន-សំរាប់អ្នកញៀនអាភៀននៅតាមក្នុងសហគមន៏ ដែលប្រើប្រាស់គ្រឿងញៀនតាមរយៈការចាក់ដោយប្រឈមមុខនឹងការរីករាលដាលនៃជំងឺអេដស៏ ។ ការផ្តល់ការព្យាបាលជំនួសគួរបញ្ចូលទៅក្នុងកិច្ចអន្តរាគមន៏ និងសេវាទាំងឡាយសំរាប់ការបង្ការការឆ្លងមេរោគអេដស៏ ព្រមទាំងកិច្ចអន្តរាគមន៏ និងសេវាទាំងឡាយសំរាប់ព្យាបាល និងថែទាំអ្នកផ្ទុកមេរោគអេដស៏ ។

---

"ការអនុវត្តន៏នូវការព្យាបាលជំនួស ត្រូវតែធ្វើឡើងទៅតាមភ័ស្តុតាងដែលទទួលបានពីការស្រាវជ្រាវ និងត្រូវបានគាំទ្រដោយការបណ្តុះបណ្តាល និងការវាយតំលៃត្រឹមត្រូវ ។ គេត្រូវការកាត់បន្ថយអោយស្ថិតនៅក្នុងក៏រិតអប្បបរមានូវផលវិបាកអវិជ្ជមាន ដោយការប្រកាន់ខ្ជាប់ខ្ជួននូវការអនុវត្តន៏វេជ្ជសាស្ត្រល្អបំផុត ការត្រួតពិនិត្យតាមដានគុណភាព និងលទ្ធផលនៃការព្យាបាល ការបង្កើតនូវវិធាការត្រួតពិនិត្យសមស្រប និងបទបញ្ជា ដើម្បីជៀសវាងនូវការបង្វែឱសថ ទៅជាការប្រើប្រាស់ដោយខុសច្បាប់ ។"

*ការព្យាបាលដោយសារធាតុជំនួស (substitution maintenance therapy) នៅក្នុងការគ្រប់គ្រងការញៀនអាភៀន និងការបង្ការជំងឺអេដស៏: ឯកសារគោលជំហរ*

*២០០៤.* ISBN 92 9061 271 1

*បោះពុម្ពដោយអង្គការសុខភាពពិភពលោក ដោយមានការគាំទ្រពីក្រុមអ្នករក្សាសិទ្ធ ។ រក្សាសិទ្ធគ្រប់យ៉ាង ។*

*អត្ថបទបោះពុម្ពផ្សាយរបស់អង្គការសុខភាពពិភពលោក អាចរកបានពីផ្នែកទីផ្សារ និងការផ្សព្វផ្សាយរបស់អង្គការសុខភាពពិភពលោក តាមរយៈអាស័យដ្ឋាន: 20 Avenue Appia, 1211 Geneva 27, Switzerland (tel: +41 22 791 2476; fax: +41 22 791 4857; email*: bookorders@who.int*) ។*

*សំណើ ដើម្បីសុំការអនុញ្ញាតិចំលងឡើងវិញ ឬដើម្បីបកប្រែនូវអត្ថបទបោះពុម្ពផ្សាយរបស់អង្គការ សុខភាពពិភពលោក - សំរាប់ការលក់ ឬការចែកចាយដោយមិនយកកំរៃ - ត្រូវផ្ញើរទៅកាន់ផ្នែកបោះពុម្ពផ្សាយ ដែលមាន អាស័យដ្ឋានដូចខាងលើ (fax: +41 22 791 4806; email: permissions@who.int) ។*

*ឯកសារនេះអាចរកបានពីអាស័យដ្ឋាន:* http://www.who.int/substance_abuse/
http://www.unodc.org/
http://www.unaids.org/

*ដើម្បីទទួលបាននូវអត្ថបទបោះពុម្ពនៃឯកសារនេះសូមទាក់ទង:* publications@who.int